TOYOTA TSUSHO GROUP

# ក្រមប្រតិបត្តិនិងសីលធម៌ ជាសកល

# Global Code of Conduct & Ethics

# ( C O C E )

COCE, សម្រាប់អនាគត

COCE: Code of Conduct & Ethics

# មាតិការឿង

1. សារពីលោកប្រធាន
2. ទស្សនៈវិស័យមូលដ្ឋាន
3. ក្រមប្រតិបត្តិនិងសីលធម៌ជាសកល (ទស្សនៈ១០ប្រការ)
4. តារាងបញ្ជាក់អំពី COCE
5. ក្រមប្រតិបត្តិនិងសីលធម៌ជាសកល (សេចក្ដីពន្យល់)

# 1. សារពីលោកប្រធាន

ចំពោះលោកអ្នកទាំងអស់គ្នា !

ក្នុងនាមជាប្រធាន និងអគ្គនាយកដែលត្រូវបានចាត់តាំងថ្មីៗនេះ ឆ្លងកាត់តាមការពិចារណាឡើងវិញនូវការអនុវត្តក្រមប្រតិបត្តិ និង សីលធម៌ (COCE) ក្នុងកំឡុងពេលពីរឆ្នាំនេះ ខ្ញុំមានអារម្មណ៍ទទួលខុសត្រូវយ៉ាងខ្ពស់ ចំពោះថ្នាក់គ្រប់គ្រងរបស់ TTC Group ដែលបានអនុវត្តដោយមិនប្រែប្រួលដើម្បីឱ្យបានសម្រេចនូវស្តង់ដារសុវត្ថិភាព និងសីលធម៌ឱ្យបានខ្ពស់។

អាជីវកម្មរបស់យើង មានការរីកដាលទូទាំងពិភពលោកយ៉ាងលឿន ហើយយើងទទួលបាននូវសក្តានុពលក្នុងទីផ្សារសំបូរបែប និងគូភាគីថ្មីៗទៀត។ ពីពេលនោះមកការធ្វើសេចក្តីសម្រេចមានភាពកាន់តែស្មុគស្មាញទៅៗ ហើយយើងត្រូវធ្វើសេចក្តីសម្រេចនេះឱ្យបានយ៉ាងលឿន។ ហើយការអនុវត្តនិងចែករំលែកនូវគុណតម្លៃជាស្នូលដែលបានមកពី COCE នៃក្រុមហ៊ុនយើងទាំងអស់គ្នា មានកាន់តែសំខាន់ទៅៗ។

ខ្ញុំឱ្យតម្លៃយ៉ាងខ្លាំងទៅលើទស្សនវិស័យរបស់ Toyota Tsusho Group ដែលជា DNA របស់ក្រុមហ៊ុនយើង "ការមើលដល់ទីកន្លែង, ការអនុវត្តផ្ទាល់, ទំនាក់ទំនងជាប់ជានិច្ច" "ការធ្វើការងារជាក្រុម" និង "ទឹកចិត្តធុរកិច្ច" និងសេចក្តីប្រាថ្នារបស់ Toyota Tsusho Group គឺការផ្តល់នូវដំណោះស្រាយចំពោះបញ្ហារបស់អតិថិជន បញ្ហារបស់សង្គម បង្កើតនូវគុណតម្លៃថ្មី និងជាវិភាគទានក្នុងការបង្កើតអនាគតរុងរឿងមួយ សម្រាប់ទាំងអស់គ្នា តាមរយៈ "របៀបធ្វើការរបស់ Toyota Tsusho"។

ខ្ញុំសូមអំពាវនាវចំពោះសមាជិកម្នាក់ៗនៃ Toyota Tsusho Group ឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីសីលធម៌ 10ប្រការនៃ COCE ហើយសូមថ្នាក់គ្រប់គ្រងទាំងអស់ណែនាំបុគ្គលិកក្រោមឱវាទខ្លួនឱ្យបានកាន់តែច្រើន ដើម្បីជានាឱ្យអ្នកទាំងនោះយល់ដឹងជារួមថា ហេតុអ្វីបានជា COCE នេះមានសារៈសំខាន់បែបនេះ។

យើងត្រូវចាត់ទុក COCE នេះជាចំបង ឱ្យបានច្បាស់លាស់ និងជ្រួតជ្រាបក្នុងការងារប្រចាំថ្ងៃ។
ចូរតស៊ូទាំងអស់គ្នា !

ថ្ងៃទី 2 ខែកក្កដា ឆ្នាំ 2018

TOYOTA TSUSHO CORPORATION
ប្រធាន និង អគ្គនាយកប្រតិបត្តិ
Ichiro Kashitani

# 2. ទស្សនៈវិស័យមូលដ្ឋាន

## ទស្សនៈវិស័យរបស់ក្រុមហ៊ុន

រួមរស់និងរីកចម្រើនជាមួយប្រជាពលរដ្ឋ សង្គម ព្រមទាំងផែនដី ដើម្បីឱ្យទៅជាក្រុមហ៊ុនមួយបង្កើតតម្លៃដែលជាវិភាគទានក្នុងការបង្កើតសង្គមរុងរឿងមួយ។

## សេចក្ដីណែនាំស្ដីពីសកម្មភាព

ក្នុងនាមជាក្រុមហ៊ុនដែលជាប្រជាពលរដ្ឋល្អម្នាក់
យើងត្រូវខំប្រឹងប្រែងធ្វើសកម្មភាពដោយចំហរ និងប្រកបដោយយុត្តិធម៌
យើងត្រូវតែមានការទទួលខុសត្រូវក្នុងសង្គម និង ខំប្រឹងប្រែងរក្សាការពារបរិស្ថាន
យើងត្រូវមានគំនិតច្នៃប្រឌិត និង ខំប្រឹងប្រែងផ្តត់ផ្គង់នូវតម្លៃបន្ថែម  ហើយ
យើងត្រូវគោរពមនុស្សជាតិ និងខំប្រឹងប្រែងបង្កើតកន្លែងធ្វើការដែលគេចង់ធ្វើ។




មាគ៌ារបស់ Toyota Tsusho Group

# 3. ក្រមប្រតិបត្តិនិងសីលធម៌ជាសកល (ទស្សនៈ១០ប្រការ)

1) យើងទាំងអស់គ្នាត្រូវខំប្រឹងប្រែងធ្វើសកម្មភាព “ANZEN”ដើម្បីបង្កើតនូវបរិស្ថានការងារមួយដែលប្រកបដោយសុវត្ថិភាពនិងសុខភាព។

2) យើងគោរពច្បាប់ព្រមទាំងបទដ្ឋានគតិយុត្តនានាដែលត្រូវបានអនុវត្ត រួមទាំងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ច្បាប់ប្រឆាំងនឹងការផ្តាច់មុខ ច្បាប់ប្រកួតប្រជែង និងច្បាប់ពាណិជ្ជកម្ម ព្រមទាំងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ។

3) យើងត្រូវប្រកាសរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ។

4) យើងត្រូវទទួលខុសត្រូវចំពោះការគោរពវិន័យផ្ទៃក្នុងទាំងអស់។

5) យើងត្រូវធ្វើសកម្មភាពប្រកបដោយសុចរិត ស្មោះត្រង់ មានតម្លាភាព ព្រមទាំងការពារនិងអភិវឌ្ឍជំនឿទុកចិត្តនៃអ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ទាំងអស់។

6) យើងត្រូវធ្វើវិភាគទានចំពោះការអភិវឌ្ឍសង្គមប្រកបដោយនិរន្តភាព។

7) យើងត្រូវធ្វើ និងជម្រុញនូវសកម្មភាពដែលល្អចំពោះបរិស្ថាន។

8) យើងត្រូវផ្តល់នូវតម្លៃបន្ថែមតាមរយៈការច្នៃប្រឌិត និង “Kaizen” (ការកែលំអជាប្រចាំ)។

9) យើងត្រូវគោរពសិទ្ធិមនុស្ស។

10) យើងត្រូវគោរពនិងប្រើភាពសំបូរបែប ទាំងក្នុងក្រុមហ៊ុន ទាំងក្នុងសង្គម។

# 4. តារាងបញ្ជាក់អំពីCOCE



# 5. ក្រមប្រតិបត្តិនិងសីលធម៌ជាសកល (សេចក្តីពន្យល់)

## 1) យើងទាំងអស់គ្នាត្រូវខំប្រឹងប្រែងធ្វើសកម្មភាព "ANZEN" ដើម្បីបង្កើតនូវបរិស្ថានការងារមួយដែលប្រកបដោយសុវត្ថិភាពនិងសុខភាព។

សុវត្ថិភាពនិងសុខភាពរបស់សមាជិកយើងទាំងអស់គ្នា គឺជាមូលដ្ឋានគ្រឹះនៃសកម្មភាពរបស់ក្រុមហ៊ុនយើង។

ហេតុនេះហើយ

- យើងត្រូវចាត់វិធានការសមស្របដើម្បីការពារសុវត្ថិភាពនិងសុខភាពគ្នាទៅវិញទៅមក ព្រមទាំងអ្នកដែលទទួលឥទ្ធិពលពីសកម្មភាពរបស់ក្រុមហ៊ុនយើងទាំងអស់គ្នា។
- យើងត្រូវគោរពច្បាប់ បទដ្ឋានគតិយុត្ត និងស្តង់ដារផ្ទៃក្នុងនានាដែលពាក់ព័ន្ធនឹងសុវត្ថិភាពនិងសុខភាព។
- យើងត្រូវចូលរួមយ៉ាងសកម្មក្នុងវគ្គបណ្តុះបណ្តាលនិងសកម្មភាពនានាស្តីពីសុវត្ថិភាពនិងសុខភាព។
- យើងនឹងប្រើព្រមទាំងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសុខភាពរបស់យើង។

## 2) យើងគោរពច្បាប់ព្រមទាំងបទដ្ឋានគតិយុត្តនានាដែលត្រូវបានអនុវត្ត រួមទាំងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ច្បាប់ប្រឆាំងនឹងការផ្តាច់មុខ ច្បាប់ប្រកួតប្រជែង និងច្បាប់ពាណិជ្ជកម្ម ព្រមទាំងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ។

ការគោរពច្បាប់ គឺជាការចាំបាច់សម្រាប់គ្រប់សកម្មភាពរបស់ក្រុមហ៊ុនយើងខ្ញុំ។ ទង្វើមិនគោរពច្បាប់តែម្តង ក៏ធ្វើឱ្យអន្តរាយខូចឈ្មោះ ព្រមទាំងតម្លៃក្រុមហ៊ុនយើងយ៉ាងធ្ងន់ធ្ងរ។

ហេតុនេះហើយ
- យើងត្រូវយល់ដឹងអំពីច្បាប់និងបទដ្ឋានគតិយុត្តទាំងអស់ (រួមទាំងវិន័យអន្តរជាតិ) ដែលត្រូវបានអនុវត្តនៅកន្លែងដែលយើងទទួលខុសត្រូវ ហើយត្រូវគោរពឱ្យបានខ្ជាប់ខ្ជួនគ្រប់ពេលវេលា។
- ក្នុងករណីដែលយើងមិនយល់ច្បាស់អំពីច្បាប់ពាក់ព័ន្ធ យើងត្រូវតែទៅពិគ្រោះនឹងនាយកដ្ឋានកិច្ចការច្បាប់ ឬអ្នកដែលមានលក្ខណៈសម្បត្តិពិគ្រោះអំពីច្បាប់។
- យើងត្រូវតែធ្វើរបាយការណ៍អំពីការមិនគោរពច្បាប់ តាមរយៈបណ្តាញសមស្របដែលបានផ្តល់ជូន។

ការបំពានច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយច្បាប់ប្រឆាំងនឹងការផ្តាច់មុខ ច្បាប់ប្រកួតប្រជែង និងច្បាប់ពាណិជ្ជកម្ម ព្រមទាំងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ ទោះជាម្តងក៏ដោយ ក៏អាចនាំឱ្យមានការពិន័យយ៉ាងធ្ងន់ធ្ងរ ក៏ដូចជាមានទោសព្រហ្មទណ្ឌ ហើយធ្វើឱ្យខូចឈ្មោះទាំងបុគ្គល ទាំងក្រុមហ៊ុនយ៉ាងធ្ងន់ធ្ងរ មិនអាចស្តារឡើងវិញបាន។

ហេតុនេះហើយ
- យើងត្រូវយល់ឱ្យច្បាស់អំពីច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ច្បាប់ប្រឆាំងនឹងការផ្តាច់មុខ និងច្បាប់ពាណិជ្ជកម្ម ព្រមទាំងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ ហើយគោរពឱ្យបានហ្មត់ចត់គ្រប់ពេលវេលា។
- យើងមិនត្រូវអញ្ជើញគេបាយ ឬទទួលនូវការអញ្ជើញបាយ ឬកំសាន្ត ឬជូន ឬទទួលនូវអំណោយណាមួយដែលខុសច្បាប់ ឬខុសសីលធម៌ជាដាច់ខាត។
- យើងត្រូវប្រកួតប្រជែងដោយយុត្តិធម៌ក្នុងទីផ្សារ ត្រូវជៀសវាងនូវសកម្មភាពដែលអាចបំពានច្បាប់ប្រឆាំងនឹងការផ្តាច់មុខ ច្បាប់ប្រកួតប្រជែង ព្រមទាំងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ។
- ពេលជួបនឹងគូប្រជែង យើងត្រូវប្រយ័ត្នពិសេស មិនត្រូវជជែកអំពីព័ត៌មានដែលពាក់ព័ន្ធនឹងចំណែកទីផ្សារ យុទ្ធសាស្ត្រនៃការលក់ តម្លៃ និងយុទ្ធសាស្ត្រតម្លៃ។
- យើងត្រូវមានការយល់ដឹងថា មានការហាម ឬការកម្រិតនូវការជួញដូរអំពីទំនិញពិសេស ឬការជួញដូរនឹងកន្លែងពិសេស ឬភាគីពិសេស ហើយរាល់ប្រតិបត្តិការអន្តរជាតិ ត្រូវគោរពច្បាប់និងបទដ្ឋានគតិយុត្តដែលមាន ឱ្យបានត្រឹមត្រូវ។

## 3) យើងត្រូវប្រកាសរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ។

ក្នុងនាមជាក្រុមហ៊ុនដែលចុះជាសមាជិកនៃទីផ្សារហ៊ុន ការប្រកាសរបាយការណ៍ហិរញ្ញវត្ថុសុក្រឹត គឺសំខាន់ណាស់ សម្រាប់យើងផង សម្រាប់អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផង។

ហេតុនេះហើយ

- យើងត្រូវធ្វើការបញ្ជាក់ឱ្យបានហ្មត់ចត់ពិសេស ស្តីពីតួលេខដែលយើងប្រកាស ឬធ្វើរបាយការណ៍។
- យើងត្រូវអនុវត្តតាមគោលការណ៍គណនេយ្យដែលត្រូវបានដាក់ឱ្យអនុវត្ត។
- យើងត្រូវប្រកាសព័ត៌មានស្តីពីហិរញ្ញវត្ថុរបស់ក្រុមហ៊ុនយើងឱ្យត្រូវតាមពេលវេលា និងឱ្យត្រឹមត្រូវ និងតាមទម្រង់ដែលមិនងាយយល់ច្រឡំ។
- យើងត្រូវរក្សាទុកនូវកំណត់ស្តីពីប្រតិបត្តិការនានាឱ្យអាចជឿទុកចិត្តបាន ឱ្យបានត្រឹមត្រូវ និងឱ្យអាចបញ្ជាក់បាន។

## 4) យើងត្រូវទទួលខុសត្រូវចំពោះការគោរពវិន័យផ្ទៃក្នុងទាំងអស់។

- យើងត្រូវយល់ ហើយត្រូវគោរពវិន័យផ្ទៃក្នុង។
- យើងត្រូវទទួលខុសត្រូវចំពោះគណនេយ្យភាពនៃទង្វើផ្ទុយនឹងវិន័យផ្ទៃក្នុង ហើយត្រូវយល់ថា បើសិនជាបានប្រព្រឹត្តអំពើអ្វីមួយផ្ទុយនឹងវិន័យផ្ទៃក្នុងនេះ អាចនឹងទទួលនូវការដាក់វិន័យ។

## 5) យើងត្រូវធ្វើសកម្មភាពប្រកបដោយសុចរិត ស្មោះត្រង់ មានតម្លាភាព ព្រមទាំងការពារនិងអភិវឌ្ឍជំនឿទុកចិត្តនៃអ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ទាំងអស់។

ក្នុងនាមជាក្រុមហ៊ុនដែលជាប្រជាពលរដ្ឋល្អមួយរូប យើងប្តេជ្ញាចិត្តថា យើងស្មោះត្រង់ សុចរិត និងមានតម្លាភាពចំពោះមុខច្បាប់និងវិន័យនានា។ តាមរយៈការប្តេជ្ញាចិត្តនេះ យើងជឿជាក់ថា អាចបង្កើតជំនឿទុកចិត្តនឹងអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ទាំងអស់ ហើយអាចបង្កើតមូលដ្ឋានគ្រឹះនៃសកម្មភាពរបស់ក្រុមហ៊ុនយើងបាន។

ហេតុនេះហើយ

- យើងមិនមែនគិតតែផលចំណេញរបស់យើងទេ។ យើងក៏គិតដល់ផលប្រយោជន៍របស់អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍នានា ហើយខំប្រឹងប្រែងធ្វើយ៉ាងណាឱ្យគេមានជំនឿមកលើយើង។
- យើងធ្វើតែសកម្មភាពណាដែលអាចធន់នឹងការវាយតម្លៃអំពីសីលធម៌ពីសំណាក់សង្គមក្នុងតំបន់និងសហគមន៍អន្តរជាតិ។
- យើងត្រូវគោរព និងការពារព័ត៌មានសម្ងាត់ ព័ត៌មានបុគ្គល កម្មសិទ្ធិបញ្ញា និងការសម្ងាត់នៃធុរកិច្ច ជាដើម ទាំងរបស់យើង ទាំងរបស់គេ។
- យើងមិនធ្វើប្រតិបត្តិការជាមួយនឹងអ្នកដែលប្រព្រឹត្ត ឬអ្នកដែលមានទំនាក់ទំនងនឹងឧក្រិដ្ឋកម្មដែលគេរៀបចំ ឬសកម្មភាពខុសច្បាប់។
- យើងមិនត្រូវបញ្ចេញសំដីមិនពិត ឬដែលនាំឱ្យគេយល់ខុស ហើយមិនត្រូវប្រព្រឹត្តអំពើប្រមាថមើលងាយ ឬបង្អាប់បង្ខូចគេ។ បើសិនជាមានកំហុស ត្រូវតែកែតម្រូវជាបន្ទាន់។
- ក្នុងករណីដែលផលប្រយោជន៍របស់បុគ្គលមានទំនាស់នឹងការទទួលខុសត្រូវរបស់ក្រុមហ៊ុន យើងត្រូវតែប្រាប់ដល់ក្រុមហ៊ុន ហើយមិនយកផលប្រយោជន៍បុគ្គលជាអាទិភាព ជាងផលប្រយោជន៍របស់ក្រុមហ៊ុនឡើយ។
- យើងមិនយកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមកប្រើសម្រាប់ក្រៅពីគោលដៅរបស់ក្រុមហ៊ុនឡើយ។
- យើងមិនប្រព្រឹត្ត ឬមិនទាក់ទងនឹងប្រតិបត្តិការរនុកក្នុងឡើយ។

## 6) យើងត្រូវធ្វើវិភាគទានចំពោះការអភិវឌ្ឍសង្គមប្រកបដោយនិរន្តរភាព។

យើងជឿជាក់យ៉ាងខ្លាំងថា ភាពសុខដុម ព្រមទាំងការអភិវឌ្ឍជាមួយមនុស្សជាតិ សង្គម និងផែនដី គឺជាគន្លឹះនៃជោគជ័យប្រកបដោយនិរន្តរភាពរបស់យើង។

ហេតុនេះហើយ

- តាមរយៈការធ្វើការជាមួយនឹងអាជីវករក្នុងតំបន់ សហគមន៍ ព្រមទាំងរដ្ឋអំណាចមូលដ្ឋានជុំវិញពិភពលោក យើងអាចក្តាប់បានជានិច្ចជាកាលនូវតម្រូវការរបស់សហគមន៍ និងពិភពលោក ហើយអាចវិភាគទានដល់ការបង្កើតមូលដ្ឋានគ្រឹះដើម្បីអភិវឌ្ឍឧស្សាហកម្មនិងសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។
- យើងជម្រុញយ៉ាងខ្លាំងក្លានូវសកម្មភាពនានាទូទាំងពិភពលោក ដែលជាវិភាគទានដល់សង្គម ជាពិសេស ដូចជាវិស័យអប់រំ វិស័យសង្គមកិច្ច និងបរិស្ថាន។

## 7) យើងត្រូវធ្វើ និងជម្រុញនូវសកម្មភាពដែលល្អចំពោះបរិស្ថាន។

ការធ្វើឱ្យសកម្មភាពរបស់ក្រុមហ៊ុនយើងមានភាពសុខដុមនឹងបរិស្ថាន គឺជាទស្សនៈវិស័យមូលដ្ឋានដែលជាឫសគល់យ៉ាងជ្រៅរបស់យើង។

ហេតុនេះហើយ

- យើងត្រូវគោរពឱ្យត្រឹមត្រូវនូវច្បាប់និងស្តង់ដារស្តីពីបរិស្ថាន។
- យើងត្រូវអភិវឌ្ឍបច្ចេកទេស សេវាកម្ម ផលិតផល និងគំរូពាណិជ្ជកម្មដែលល្អសម្រាប់បរិស្ថាន។
- ក្នុងសកម្មភាពរបស់ក្រុមហ៊ុន យើងត្រូវខំប្រឹងប្រែងកាត់បន្ថយកាកសំណល់ ប្រើ និង កែច្នៃឡើងវិញ។
- ពេលធ្វើសកម្មភាពរបស់ក្រុមហ៊ុន យើងត្រូវពិចារណាដល់ផលប៉ះពាល់នៃសកម្មភាពរបស់យើងដែលមានទៅលើបរិស្ថាន តាមរយៈប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់យើង។
- យើងត្រូវត្រួតពិនិត្យនិងវាយតម្លៃផលប៉ះពាល់នៃសកម្មភាពក្រុមហ៊ុនយើងទៅលើបរិស្ថាន តាមរយៈប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់យើង។

## 8) យើងត្រូវផ្តល់នូវតម្លៃបន្ថែមតាមរយៈការច្នៃប្រឌិត និង “Kaizen” (ការកែលំអជាប្រចាំ)។

ដើម្បីឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តភាព ហើយមានវិភាគទានក្នុងការប្តូរសង្គម យើងត្រូវតែបង្កើតគំនិតថ្មីៗ និងតម្លៃបន្ថែមសម្រាប់សង្គម និងកែលំអសកម្មភាពក្រុមហ៊ុនជាប្រចាំ ខានមិនបាន។

ហេតុនេះហើយ

- យើងត្រូវតភ្ជាប់ និងចែករំលែកនូវគំនិតផ្សេងៗ បច្ចេកវិទ្យា ព្រមទាំងឯកទេស តាមរយៈបណ្តាញទូទាំងពិភពលោក និងសកម្មភាពក្រុមហ៊ុនពីលទ្ធកម្មវត្ថុធាតុដើម រហូតដល់ផ្គត់ផ្គង់ផលិតផលជូនអតិថិជន។
- យើងត្រូវកែលំអជាប្រចាំនូវគំរូធុរកិច្ច និងដំណើរការរបស់យើង តាមរយៈសកម្មភាព PDCA និង Kaizen ។
- យើងត្រូវពង្រីកយ៉ាងសកម្មនូវគំនិតច្នៃប្រឌិត និង Kaizen ទៅលើសកម្មភាពពីលទ្ធកម្មវត្ថុធាតុដើមរហូតដល់ការផ្គត់ផ្គង់ផលិតផលចំពោះអតិថិជន និងទៅលើវិស័យធុរកិច្ចថ្មី។

## 9) យើងត្រូវគោរពសិទ្ធិមនុស្ស។

ការគោរពមនុស្សជាតិ បានចាក់ឫសយ៉ាងជ្រៅទៅក្នុងទស្សនៈវិស័យមូលដ្ឋានរបស់យើង។ យើងមិនអនុញ្ញាតដាច់ខាត នូវការបំពានសិទ្ធិមនុស្ស ទោះជាក្នុងទម្រង់ណាមួយក៏ដោយ។

ជាពិសេស ៖

- យើងមិនចូលរួម ឬមិនប្រព្រឹត្តធុរកិច្ចណាដែលប្រឆាំងនឹងភាពថ្លៃថ្នូររបស់មនុស្សជាតិឡើយ។
- យើងមិនត្រូវរើសអើងពូជសាសន៍ ពណ៌សម្បុរ សាសនា ឬសញ្ជាតិឡើយ។
- យើងមិនពាក់ព័ន្ធនឹងពលកម្មលើកុមារ ការជួញដូរមនុស្ស ឬពលកម្មដោយបង្ខំ ឬមិនស្ម័គ្រចិត្តជាដើមឡើយ។
- យើងមិនអនុញ្ញាតការយាយីផ្លូវភេទជាដាច់ខាត ទោះជាទម្រង់ណាក៏ដោយ។
- យើងមិនប្រព្រឹត្ត ឬមិនពាក់ព័ន្ធនឹងអ្នកប្រព្រឹត្តអំពើបំពានសិទ្ធិមនុស្សឡើយ។

## 10) យើងត្រូវគោរពនិងប្រើភាពសំបូរបែប ទាំងក្នុងក្រុមហ៊ុន ទាំងក្នុងសង្គម។

យើងជឿជាក់ថា ការគោរពនិងការប្រើភាពសំបូរបែប គឺជាប្រភពនៃការវិវត្ត និងការរីកចម្រើន។ ភាពសំបូរបែបរបស់យើង ធ្វើឱ្យយើងមានចក្ខុវិស័យផ្សេងៗ ដើម្បីឆ្លើយតបនឹងការប្រែប្រួលបរិស្ថានធុរកិច្ចដែលកើនឡើងយ៉ាងខ្លាំង និងឆ្លើយតបចំពោះតម្រូវការរបស់អតិថិជនទូទាំងពិភពលោក។

ហេតុនេះហើយ

- យើងត្រូវជម្រុញនូវកន្លែងធ្វើការសំបូរបែប ដែលមនុស្សពូជសាសន៍ផ្សេងគ្នា សញ្ជាតិផ្សេងគ្នា ភេទនិងអាយុផ្សេងគ្នា ធ្វើការជាមួយគ្នាយ៉ាងសកម្ម។
- យើងត្រូវផ្តល់ឱកាសស្មើគ្នាដល់សមាជិកទាំងអស់ ទោះជាពូជសាសន៍ សញ្ជាតិ ភេទអ្វីក៏ដោយ។
- យើងត្រូវជម្រុញនូវការប្រាស្រ័យទាក់ទងចំហរ រវាងសមាជិកគ្រប់ជាន់ថ្នាក់ និងគ្រប់អង្គភាព។
- យើងត្រូវបង្កើននូវឧត្តមភាពក្នុងការប្រជែង តាមរយៈការប្រើជំនាញសមាហរណកម្មការគ្រប់គ្រងរបស់យើង។

***<u>កំណត់សំខាន់:</u>***

***ដើម្បីសម្រេចនូវខ្លឹមសារនៃ COCE***

- ***សមាជិកទាំងអស់ត្រូវធ្វើរបាយការណ៍អំពីការបំពាន COCE នេះ តាមរយៈបណ្តាញសមស្របដែលត្រូវបានរៀបចំជូន។***
- ***ក្រុមហ៊ុនធានាចំពោះអ្នកដែលបានធ្វើរបាយការណ៍ដោយស្មោះត្រង់អំពីការបំពាន COCE នេះ  មិនសងសឹក ឬមិនចាត់វិធានការអ្វីមួយចំពោះអ្នកនោះឡើយ។***
- ***សមាជិកទាំងអស់ត្រូវសហការទាំងស្រុងនឹងក្រុមហ៊ុន ក្នុងការស៊ើបអង្កេតអំពីការបំពាន COCE នេះ។***

**TOYOTA TSUSHO CORPORATION**
Compliance & Crisis Management Dept.
Compliance Management Group
First Edition July 1st , 2016
Second Edition July 2nd , 2018

TOYOTA TSUSHO CORPORATION